អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤

## សេចក្តីប្រកាសព័ត៌មាន
## អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមានការតែងតាំងមេធាវីប្រចាំការសម្រាប់ ខៀវ សំផន

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបដិសេធសំណើសុំរបស់សហ-ព្រះរាជអាជ្ញា ដើម្បីតែងតាំងជាបណ្តោះអាសន្ននូវក្រុមមេធាវីដែលជាមិត្តរបស់តុលាការ និងបានបង្គាប់ឱ្យអង្គភាពគាំពារការពារក្តីតែងតាំងក្រុមមេធាវីការពារក្តីប្រចាំការរបស់តុលាការជាជនជាតិកម្ពុជាម្នាក់ និងអន្តរជាតិម្នាក់សម្រាប់លោក ខៀវ សំផន។

អង្គជំនុំជម្រះសាលាដំបូងចាត់វិធានការនេះ ដោយសារតែលទ្ធផលនៃការរកឃើញថា ការប្រព្រឹត្តរបស់ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ក្នុងរយៈពេលពីរខែកន្លងទៅនេះបានខកខានចូលរួមសវនាការ រួមទាំងបានរារាំងកិច្ចដំណើរការនីតិវិធីផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងបានចាត់វិធានការនេះដោយយល់ឃើញថាដើម្បីការពារកុំឲ្យមានការរារាំងកិច្ចដំណើរការនីតិវិធីកើតមានឡើងម្តងទៀត។

តួនាទីរបស់មេធាវីប្រចាំការគឺត្រូវត្រៀមខ្លួន និងធានាលទ្ធភាពក្នុងការទទួលកិច្ចការការពារក្តីឱ្យ ខៀវ សំផន បានគ្រប់ពេលក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់។ ក្រុមមេធាវីការពារក្តីប្រចាំការគឺជាក្រុមមេធាវីដែលឯករាជ្យពីក្រុមមេធាវីការពារក្តីបច្ចុប្បន្ន ហើយពួកគាត់នឹងមិនធ្វើការប្រឹក្សាយោបល់ ឬទទួលការបង្គាប់បញ្ជាណាមួយពីជនជាប់ចោទ ខៀវ សំផន ទេ លុះត្រាតែអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យធ្វើដូច្នោះ។ ក្រុមមេធាវីប្រចាំការទាំងនេះត្រូវតែចូលរួមរាល់សវនាការទាំងអស់ក្នុងសំណុំរឿង ០០២/០២ ដើម្បីឲ្យពួកគាត់បានយល់ដឹងពីសំណុំរឿងនេះ។

ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យក្រុមមេធាវីការពារក្តីប្រចាំការជំនួសមេធាវីបច្ចុប្បន្នសម្រាប់លោក ខៀវ សំផន ពួកគេនឹងបំពេញការងារក្នុងឋានៈជាក្រុមមេធាវីការពារក្តីដែលតែងតាំងដោយតុលាការ។ ក្រុមមេធាវីការពារក្តីទាំងនេះ ត្រូវស្តាប់ការបង្គាប់របស់តុលាការ ហើយអនុវត្តតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh

សេចក្តីសម្រេចនេះអាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក
www.eccc.gov.kh/document/court/TC-5-December-2014

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh